**សំណួរ៖** តើអ្នកផលិតពូជដំណាំ ឬ អ្នកលក់ពូជដំណាំ ត្រូវទទួលខុសត្រូវលើគុណភាពដែរឬទេ?

**ចម្លើយ៖** តាមមាត្រា ៤៨ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ ២០០៨ ពួកគេត្រូវ ទទួលខុសត្រូវលើគុណភាពនៃពូជដំណាំ ក្នុងករណីដែលមិនដូចអ្វីចែងលើសំបកវេចខ្ចប់ ឬ ស្លាកសញ្ញា។ ការតវ៉ាត្រូវធ្វើឡើងក្នុងរយៈពេល ៣០ ថ្ងៃក្រោយពីការទិញពូជដំណាំ រហូតដល់យកទៅសាបព្រោះ បណ្តុះឬដាំ(មាត្រា ៤៩)។ ការបំពាននេះ នឹងត្រូវទទួលរងនូវការពិន័យអន្តរការណ៍ចំនួនទឹកប្រាក់ពីរដង នៃតម្លៃវត្ថុ តាងពិតប្រាកដលើទីផ្សារ និងពិន័យអន្តរការណ៍ទ្វេរដង ក្នុងករណីមិនរាងចាល និងដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬបញ្ជូនសំណុំរឿងទៅតុលាការ (មាត្រា ៧៩)។